លម្អៀងពីការប្តូររូបិយប័ណ្ណ	13	-	68.331	-	34.317
មូលធនសរុប		**๗๕๕.00๔**	**๓.๒๕๕.๑๔๑**	**๑.๒๗0.๔๑๕.๑๓๘.๘๑๖**	
បំណុល					
ប្រាក់កម្ចី	14	2.889.581	11.772.153	2.699.631	10.920.007
ទឹកប្រាក់ជំពាក់ទៅសម្ព័ន្ធញាតិ	15	48.470	197.467	36.920	149.341
បំណុលផ្សេងៗ	16	36.70๑	149.5๒0	37.923	153.399
បំណុលពន្ធលើប្រាក់ចំណូលរយៈពេលខ្លី	17	144.832	590.046	113.807	460.349
បំណុលសរុប		**3.119.58๔**	**12.709.18๖**	**2.888.281**	**11.683.096**
មូលធន និងបំណុលសរុប		**3.918.588**	**15.964.327**	**4.158.693**	**16.821.912**

១៩.របាយការណ៍លទ្ធផលពេញលេញ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

	កំណត់	2021		2020	
	សម្គាល់	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណូលការប្រាក់		960.451	3.907.115	1.039.702	4.238.865
ចំណាយការប្រាក់		(72.214)	(293.767)	(37.219)	(151.742)
ចំណូលការប្រាក់សុទ្ធ		**888.237**	**3.613.348**	**1.002.483**	**4.087.123**
ចំណូលបានពីថ្លៃឈ្នួល និងកម្រៃជើងសារ	១៨	135.800	552.434	25.118	102.406
ចំណូលប្រតិបត្តិការសរុប		**1.024.037**	**4.165.782**	**1.027.601**	**4.189.529**
ខាតបង់ឱនភាពតម្លៃលើភតិសន្យាហិរញ្ញវត្ថុត្រូវទទួល		(90.93៥)	(369.92៤)	(141.386)	(576.431)
ចំណាយលើបុគ្គលិក	១៩	(393.848)	(1.602.174)	(304.815)	(1.242.731)
រំលស់		(26.406)	(107.420)	(24.863)	(101.366)
ចំណាយប្រតិបត្តិការផ្សេងទៀត	២០	(940.928)	(3.827.695)	(140.894)	(574.425)
(ខាត)/ចំណេញមុនបង់ពន្ធ		**(428.0៨0)**	**(1.741.4៣១)**	**415.643**	**1.694.576**
ចំណាយពន្ធលើប្រាក់ចំណូល	២១	(43.328)	(176.258)	(84.569)	(344.788)
(ខាត)/ចំណេញសម្រាប់ការិយបរិច្ឆេទ		**(471.40៨)**	**(1.917.68៩)**	**331.074**	**1.349.788**
លទ្ធផលចំណេញ/(ខាត)លម្អិតផ្សេងៗក្រោយបង់ពន្ធ					
ការបកប្រែរូបិយប័ណ្ណបរទេស		-	34.014	-	(38.774)
លទ្ធផលលម្អិត(ខាត)/ចំណេញសរុបសម្រាប់ការិយបរិច្ឆេទ		**(471.40៨)**	**(1.883.67៥)**	**331.074**	**1.311.014**

២០.របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

	ដើមទុន		ទុនបម្រុងតាមបទប្បញ្ញត្តិ		(ខាតបង្គរ)/ចំណេញរក្សាទុក		លម្អៀងពីការប្តូររូបិយប័ណ្ណ	មូលធនសរុប	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
នាថ្ងៃទី១ ខែមករា ឆ្នាំ ២០២១	1.000.000	4.000.000	-	-	270.412	1.104.499	34.317	1.270.412	5.138.816
ខាតលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ									
ខាតសម្រាប់ការិយបរិច្ឆេទ	-	-	-	-	(471.40៨)	(1.917.68៩)	-	(471.40៨)	(1.917.68៩)
ផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ	-	-	410.648	1.672.980	(410.648)	(1.672.980)	-	-	-
ចំណេញលម្អិតផ្សេងៗ សម្រាប់ការិយបរិច្ឆេទ	-	-	-	-	-	-	34.014	-	34.014
ខាតលម្អិតសរុប	-	-	410.648	1.672.980	(882.05៦)	(3.590.66៩)	34.014	(471.40៨)	(1.883.67៥)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២១	1.000.000	4.000.000	410.648	1.672.980	(611.64៤)	(2.486.1៧0)	68.331	799.00៤	3.255.149

១៩.របាយការណ៍បម្រែបម្រួលមូលធន (ត)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ (ត)

	ដើមទុន		(ខាតបង្គរ)/ចំណេញរក្សាទុក		លម្អៀងពីការប្តូរប្រាក់	មូលធនសរុប	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
នាថ្ងៃទី១ ខែមករា ឆ្នាំ២០២០	1.000.000	4.000.000	(60.662)	(245.289)	73.091	939.338	3.827.802
ចំណេញលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ							
ចំណេញសម្រាប់ការិយបរិច្ឆេទ	-	-	331.074	1.349.788	-	331.074	1.349.788
ខាតលម្អិតផ្សេងៗសម្រាប់ការិយបរិច្ឆេទ	-	-	-	-	(38.774)	-	(38.774)
ចំណេញលម្អិតសរុប	-	-	331.074	1.349.788	(38.774)	331.074	1.311.014
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០	1.000.000	4.000.000	270.412	1.104.499	34.317	1.270.412	5.138.816

២១.របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

	កំណត់សម្គាល់	2021		2020	
		ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ					
(ខាត)/ចំណេញមុនបង់ពន្ធ		(428.0៨0)	(1.741.4៣9)	415.643	1.694.57៦
<u>និយ័តកម្មលើធាតុមិនមែនជាសាច់ប្រាក់៖</u>					
ចំណូលពីការប្រាក់		(960.451)	(3.907.115)	(1.039.702)	(4.238.865)
ចំណាយពីការប្រាក់		72.214	293.767	37.219	151.742
ខាតលើឱនភាពតម្លៃលើភតិសន្យា ហិរញ្ញវត្ថុត្រូវទទួល	៧	90.93៥	369.92៤	141.386	576.431
ជម្រះបញ្ជីលើភតិសន្យាហិរញ្ញវត្ថុត្រូវទទួល	២0	762.280	3.100.955	-	-
ចំណេញបានពីការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ		(182)	(740)	-	-
ខាតពីការលក់ទ្រព្យសកម្មទុកសម្រាប់ជួល		18.467	75.124	-	-
រំលស់នៃទ្រព្យសកម្ម រោងចក្រ និងបរិក្ខារ		26.406	107.420	24.863	101.366
ខាតពីប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល		(418.411)	(1.702.09៦)	(420.591)	(1.714.7៥0)
<u>បម្រែបម្រួលទុនបង្វិល៖</u>					
ទ្រព្យសកម្មទុកសម្រាប់ជួល		(124.402)	(506.067)	(157.608)	(642.568)
ភតិសន្យាហិរញ្ញវត្ថុត្រូវទទួល-សុទ្ធ		(125.217)	(509.383)	(1.430.777)	(5.833.278)
ប្រាក់តម្កល់កាតព្វកិច្ច		-	-	(25.000)	(101.925)
ទ្រព្យសកម្មផ្សេងៗ		(3.300)	(13.424)	-	-
ទឹកប្រាក់ជំពាក់ទៅសម្ព័ន្ធញាតិ	២២(ខ)	11.550	46.985	(9.580)	(39.058)
បំណុលផ្សេងៗ		(1.22២)	(4.979)	13.646	55.635
សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងប្រតិបត្តិការ		(661.00២)	(2.688.95៦)	(2.029.910)	(8.275.94៤)
ការប្រាក់បានទទួល		829.97៥	3.376.3៣៨	906.270	3.694.863
ពន្ធលើប្រាក់ចំណូលបានបង់	១៧	(27.047)	(110.027)	(11.614)	(47.350)
សាច់ប្រាក់សុទ្ធបានពី/(ប្រើប្រាស់)ក្នុង សកម្មភាពប្រតិបត្តិការ		141.926	577.35៥	(1.135.254)	(4.628.43៩)

២០.របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ (ត)

	កំណត់សម្គាល់	2021		2020	
		ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ					
ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ		(9.998)	(40.672)	(46.510)	(189.621)
ទឹកប្រាក់បានពីការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ		500	2.034	-	-
ទឹកប្រាក់បានពីការលក់ទ្រព្យសកម្ម សម្រាប់ជួល		37.150	151.126	-	-
លំហូរសាច់ប្រាក់សុទ្ធបានពី/(ប្រើប្រាស់) ក្នុងសកម្មភាពវិនិយោគ		27.652	112.488	(46.510)	(189.621)
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន					
ទឹកប្រាក់បានពីប្រាក់កម្ចីពីសម្ព័ន្ធញាតិ	២២(ខ)	494.000	2.009.592	960.000	3.913.920
ទឹកប្រាក់បានពីប្រាក់កម្ចីពីមិនសម្ព័ន្ធញាតិ		400.000	1.627.200	250.000	1.019.250
សំណងនៃប្រាក់ដើមទៅសម្ព័ន្ធញាតិ	២២(ខ)	(214.000)	(870.552)	(120.000)	(489.240)
សំណងនៃប្រាក់ដើមទៅមិនសម្ព័ន្ធញាតិ		(520.000)	(2.115.360)	(375.000)	(1.528.875)
សំណងនៃការប្រាក់		(42.264)	(171.930)	(31.026)	(126.493)
លំហូរសាច់ប្រាក់សុទ្ធបានពី សកម្មភាពហិរញ្ញប្បទាន		117.736	478.950	683.974	2.788.562
កំណើន/(តំហយ)សាច់ប្រាក់ និង សាច់ប្រាក់សមមូល		287.314	1.168.7៣	(497.790)	(2.029.4៩0)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ		71.447	289.002	569.237	2.319.641
លម្អៀងពីការប្តូររូបិយប័ណ្ណនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល		-	3.79៧	-	(1.1៤៩)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ	៨	358.761	1.461.592	71.447	289.002

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

១.ព័ត៌មានអំពីក្រុមហ៊ុន

អគីធីអិន អឺឡាយអិន ហ្វាយនែនសល លីស៊ីង ម.ក ដែលហៅកាត់ថា "ក្រុមហ៊ុន" គឺជាក្រុមហ៊ុនមានអាជ្ញាប័ណ្ណ

ភតិសន្យាហិរញ្ញវត្ថុមួយ ដែលបានបង្កើតឡើង និងមានទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិតក្រោមបញ្ជីការលេខ ០០០៣៥០៩៦។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណ ដើម្បីប្រតិបត្តិការជាភតិសន្យាហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា ("NBC") នាថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨។

ការិយាល័យចុះបញ្ជី និងអាសយដ្ឋានអាជីវកម្មរបស់ក្រុមហ៊ុន ស្ថិតនៅផ្ទះលេខ៨១E0E១E២ ផ្លូវជាតិលេខ៦A
ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់សេវាកម្មភតិសន្យាហិរញ្ញវត្ថុទៅអតិថិជន។ នៅក្នុងអំឡុងការិយបរិច្ឆេទនេះ ពុំមានការផ្លាស់ប្តូរជាសារវន្តលើសកម្មភាពអាជីវកម្មចម្បងនេះទេ។

ភាគទុនិករបស់ក្រុមហ៊ុនគឺ AMH Investment International Limited និង Ruam Pattana Leasing Co., Ltd. ដែលមានកម្មសិទ្ធិ ៧៤,៥% និង ២៥,៥% រៀងគ្នា។ ក្រុមហ៊ុន AMH Investment International Limited គឺជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលចុះបញ្ជីតាមច្បាប់របស់ហុងកុងដែលមានលេខចុះបញ្ជី ១៤២៤៤៩២ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០១០។ Ruam Pattana Leasing Co, Ltd. ត្រូវបានបញ្ចូលនៅក្រោមច្បាប់នៃសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលមានលេខចុះបញ្ជី០១-០០០១៤៨០៥ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានអនុម័ត និងអនុញ្ញាតអោយបោះផ្សាយដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

២. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

២.១ របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs)។

២.២ រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយវត្ថុជាតិនៃប្រទេសកម្ពុជាគឺប្រាក់រៀល។ ប៉ុន្តែក្រុមហ៊ុនមានប្រតិបត្តិការអាជីវកម្ម និងរក្សាកំណត់ត្រាបញ្ជីគណនេយ្យចម្បងរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក។ ក្រុមប្រឹក្សាភិបាលបានកំណត់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុនក្នុងការវាស់វែង និងបង្ហាញដោយសារវាឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងស្ថានភាពបស់ក្រុមហ៊ុន។

ការប្តូរពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ហើយបានប្រើប្រាស់អត្រាប្តូរប្រាក់បិទប្រចាំឆ្នាំ និងអត្រាប្តូរប្រាក់មធ្យមផ្លូវការដោយ ១ ដុល្លារអាមេរិកស្មើនឹង ៤.០៧៤រៀល និង ១ដុល្លារអាមេរិកស្មើនឹង ៤.០៦៨រៀលរៀងគ្នា សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១ (ឆ្នាំ២០២០៖ ៤.០៤៥រៀល និង ៤.០៧៧រៀល) ដូចដែលបានប្រកាសដោយធនាគារជាតិនៃកម្ពុជា។

ការប្រើប្រាស់អត្រាការប្រាក់ខាងលើ មិនគួរត្រូវបានប្រើប្រាស់ ជាតំណាងឲ្យប្រាក់ដុល្លារអាមេរិក ឬត្រូវបាន ឬអាចត្រូវបានបំលែងទៅជាប្រាក់រៀលក្នុងអត្រាណាមួយឡើយ។

២.៣ មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបានរៀបចំតាមវិធីសាស្ត្រថ្លៃដើមប្រវត្តិសាស្ត្រ លើកលែងមានការបង្ហាញផ្សេងពីនេះនៅក្នុងកំណត់សម្គាល់ ៣ នៃរបាយការណ៍ហិរញ្ញវត្ថុ។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ(ត)

២.៤ ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាម CIFRS for SMEs តម្រូវឲ្យប្រើប្រាស់ការប៉ាន់ស្មាន និងការសន្មតគណនេយ្យជាក់លាក់មួយចំនួន ដែលមានឥទ្ធិពលដល់ចំនួនទឹកប្រាក់របស់ទ្រព្យសកម្ម និងបំណុលដែលបានរាយការណ៍ និងការបង្ហាញពីទ្រព្យសកម្ម និងបំណុលយថាហេតុនៅកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ និងចំនួនទឹកប្រាក់ចំណូល និងចំណាយដែលបានរាយការណ៍នៅការិយបរិច្ឆេទ រាយការណ៍។ វាតម្រូវឲ្យក្រុមប្រឹក្សាភិបាលត្រូវធ្វើការវិនិច្ឆ័យ ក្នុងការអនុវត្តគោលនយោបាយគណនេយ្យនេះផងដែរ។ទោះបីជាការប៉ាន់ស្មាន និងការវិនិច្ឆ័យ ផ្អែកលើចំណេះដឹង និងព្រឹត្តិការណ៍នាពេលបច្ចុប្បន្នរបស់ក្រុមប្រឹក្សាភិបាលក៏ដោយ លទ្ធផលជាក់ស្តែងអាចខុសគ្នា។

ផ្នែកទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់៤ នៃរបាយការណ៍ហិរញ្ញវត្ថុ។

៣. សេចក្តីសង្ខេបពីគោលនយោបាយគណនេយ្យសំខាន់ៗ

លើកលែងតែមានការចែងផ្សេងពីនេះ គោលនយោបាយគណនេយ្យខាងក្រោមនេះត្រូវបានអនុវត្តដោយសង្គតិភាព គ្រប់ការិយបរិច្ឆេទដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

៣.១ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

(ក) ការទទួលស្គាល់

ក្រុមហ៊ុនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដំបូង នៅពេលដែលក្រុមហ៊ុនក្លាយជាភាគីនៃការផ្តល់កិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ។ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូង តាមតម្លៃសមស្រប បូកនឹងចំណាយប្រតិបត្តិការ ដែលរួមចំណែកដោយផ្ទាល់ទៅលើការទិញ ឬបោះផ្សាយ។

(ខ) ការចាត់ថ្នាក់

ក្រុមហ៊ុនចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុជាឧបករណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានដោយអនុលោមតាមផ្នែកទី ១១ មូលដ្ឋានឧបករណ៍ហិរញ្ញវត្ថុ។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ(ត)

(ត) ការឈប់ទទួលស្គាល់

ក្រុមហ៊ុនឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិទទួលបានសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុផុតសុពលភាព ឬត្រូវបានទូទាត់ ឬផ្ទេរសិទ្ធិកិច្ចសន្យាក្នុងការទទួលលំហូរសាច់ប្រាក់ក្នុងប្រតិបត្តិការ ដែលហានិភ័យ និងផលចំណេញនៃភាពជាម្ចាស់កម្មសិទ្ធិលើទ្រព្យសកម្មហិរញ្ញវត្ថុនោះត្រូវបានផ្ទេរ ឬក្រុមហ៊ុនមិនផ្ទេរ ឬមិនរក្សាទុកហានិភ័យ និងផលចំណេញនៃភាពជាម្ចាស់កម្មសិទ្ធិ និងមិនបានរក្សាទុកលើការគ្រប់គ្រងទ្រព្យសម្បត្តិហិរញ្ញវត្ថុទេ។ ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលកាតព្វកិច្ចកិច្ចសន្យាត្រូវបានរំសាយលុបចោល ឬហួសកាលកំណត់។

(ឃ) ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ អាចកាត់កងគ្នាបាន ហើយតម្លៃយោងសុទ្ធត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែក្រុមហ៊ុនមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីទូទាត់ និងមានបំណងធ្វើការទូទាត់លើមូលដ្ឋានតម្លៃសុទ្ធ ឬដើម្បីទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

(ង) ការវាស់វែងថ្លៃដើមរំលស់

ថ្លៃដើមរំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ គឺជាទឹកប្រាក់ ដែលទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែង នៅពេលទទួលស្គាល់ដំបូង ដកការទូទាត់ប្រាក់ដើម បូក ឬដករំលស់បង្គរ ដោយការប្រើប្រាស់មូលដ្ឋានវិធីសាស្ត្រការប្រាក់មានប្រសិទ្ធិភាពប្រសិនបើមានភាពខុសគ្នារវាងទឹកប្រាក់ដែលបានទទួលស្គាល់ដំបូង និងទឹកប្រាក់ដល់កាលកំណត់ដកការថយចុះលើឱនភាព។

(ច) ការវាស់វែងតម្លៃសមស្រប

តម្លៃសមស្របគឺជាតម្លៃ ដែលត្រូវបានទទួលបានដោយការលក់ទ្រព្យសកម្ម ឬបានទូទាត់ចំពោះការផ្ទេរបំណុល នៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមទីផ្សារនា

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ(ត)

ការិយបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬយកទីផ្សារជាអាទិភាពបំផុត ដែលក្រុមហ៊ុនអាចកំណត់រកបាននៅការិយបរិច្ឆេទនៃការវាស់វែងនោះ។ តម្លៃសមស្របរបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យនៃការមិនអនុវត្តកាតព្វកិច្ច។

ក្រុមហ៊ុនវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ ប្រសិនបើមាន។ ទីផ្សារមួយអាចចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬបំណុល កើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានអំពីតម្លៃជាទៀងទាត់។ ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេនោះក្រុមហ៊ុនត្រូវប្រើបច្ចេកទេសវាយតម្លៃណាដែលអាចប្រើប្រាស់ទិន្នន័យដែល អាចអង្កេតជាអតិបរមានិងកាត់បន្ថយនូវការប្រើប្រាស់ទិន្នន័យដែលមិនអាចអង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណានៅក្នុងការកំណត់តម្លៃ។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

៣. សេចក្តីសង្ខេបពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

៣.១ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ច) ការវាស់វែងតម្លៃសមស្រប (ត)

ភស្តុតាងដ៏ល្អបំផុតនៃតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ នៅពេលទទួលស្គាល់ជាលើកដំបូង គឺជាទូទៅ តម្លៃប្រតិបត្តិការ មានន័យថា ជាតម្លៃសមស្របនៃផលតបស្នងបានផ្តល់ឲ្យ ឬបានទទួល។ ប្រសិនបើក្រុមហ៊ុនកំណត់ថា តម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង ខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនេះ ពុំមានភស្តុតាងមកបញ្ជាក់ តាមរយៈសម្រង់តម្លៃក្នុងទីផ្សារចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃដែលក្នុងនោះទិន្នន័យ ដែលមិនអាចអង្កេតបានពាក់ព័ន្ធនឹងការវាស់វែង ត្រូវបានសន្មតថាមិនគ្រប់គ្រាន់ ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្រប ដោយកែតម្រូវតាមរយៈ ការពន្យារនូវភាពខុសគ្នារវាងតម្លៃសមស្រប នៅពេលទទួលស្គាល់ជាលើកដំបូង និងតម្លៃប្រតិបត្តិការ។ បន្ទាប់មកទៀត ភាពខុសគ្នានោះ គឺត្រូវទទួលស្គាល់នៅក្នុងចំណេញ ឬខាត ផ្អែកលើអាយុកាលរបស់ឧបករណ៍នោះ ក៏ប៉ុន្តែមិនឲ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ។ ក្រុមហ៊ុនទទួលស្គាល់ការផ្ទេររវាង កម្រិតឋានានុក្រមនៃតម្លៃសមស្របក្នុងអំឡុងការិយបរិច្ឆេទបញ្ចប់រាយការណ៍ដែលការផ្លាស់ប្តូរត្រូវបានកើតឡើង។

(ឆ) អត្តសញ្ញាណ និងការវាស់វែងនៃឱនភាពតម្លៃ

<u>ភស្តុតាងដែលបញ្ជាក់ពីឱនភាពតម្លៃ</u>

នាការិយបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនវាយតម្លៃ ថាតើមានភស្តុតាងជាក់ស្តែងនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងដោយថ្លៃដើម ឬថ្លៃដើមរំលស់។ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមទ្រព្យ សកម្មហិរញ្ញវត្ថុ ត្រូវបានធ្វើឱនភាពតម្លៃ នៅពេលមានភស្តុតាងបង្ហាញថាព្រឹត្តិការណ៍ ខាតបង់បានកើតឡើងបន្ទាប់ពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្ម ហើយព្រឹត្តិការណ៍ខាតបង់មានផលប៉ះពាល់ដល់លំហូរសាច់ប្រាក់នាពេលអនាគតនៃទ្រព្យសកម្ម ដែលត្រូវបានប៉ាន់ស្មានបាន។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

៣. សេចក្តីសង្ខេបពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

៣.១ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ឆ) អត្តសញ្ញាណ និងការវាស់វែងនៃឱនភាពតម្លៃ (ត)

<u>ភស្តុតាងដែលបញ្ជាក់ពីឱនភាពតម្លៃ (ត)</u>

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានធ្វើឱនភាពតម្លៃរួមមាន៖

- ការលំបាកផ្នែកហិរញ្ញវត្ថុជាសារវន្តរបស់អ្នកខ្ចី ឬអ្នកបោះផ្សាយ
- ភាពមិនទៀងទាត់ ឬការលុបចោលដោយអ្នកខ្ចី
- ការរៀបចំឡើងវិញនូវលក្ខខណ្ឌទូទាត់សង ដែលក្រុមហ៊ុនមិនបានរំពឹងទុក
- សញ្ញាណបង្ហាញថាកូនបំណុល នឹងជួបប្រទះការក្ស័យធន
- ការបាត់បង់នៃទីផ្សារសកម្មសម្រាប់មូលប័ត្រ ឬ
- ទិន្នន័យដែលអាចសង្កេតបានទាក់ទងនឹងក្រុមនៃទ្រព្យសកម្ម ដូចជាការផ្លាស់ប្តូរអវិជ្ជមានលើស្ថានភាពការទូទាត់របស់កូនបំណុល ឬអ្នកបោះផ្សាយនៅក្នុងក្រុម ឬលក្ខខណ្ឌសេដ្ឋកិច្ចដែលទាក់ទងនឹងលំនាំដើមនៅក្នុងក្រុម។

<u>ការវាយតម្លៃទោល និងសមូហភាព</u>

រាល់ទ្រព្យសកម្មទោលជា សារវន្តត្រូវបានវាយតម្លៃផ្សេងៗ ពីគ្នាចំពោះឱនភាពតម្លៃ។

ទ្រព្យសកម្ម ដែលត្រូវបានរកឃើញថាមិនបានធ្វើឱនភាពតម្លៃ ត្រូវបានវាយតម្លៃជាក្រុមលើឱនភាពតម្លៃ ដែលបានកើតឡើង ប៉ុន្តែមិនទាន់បានកំណត់បញ្ជាក់នៅឡើយ។សមាសធាតុនីមួយៗនៃសំវិធានធនលើឱនភាពតម្លៃ ត្រូវបានអនុវត្តទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានវាយតម្លៃទោលចំពោះឱនភាពតម្លៃ ហើយត្រូវបានគេរកឃើញថាមានឱនភាពតម្លៃ ហើយផ្អែកលើការប៉ាន់ស្មានដ៏ប្រសើរបំផុតរបស់គណៈគ្រប់គ្រង លើតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ដែលរំពឹងថានឹងទទួលបាន។ក្នុងការប៉ាន់ស្មានលំហូរសាច់ប្រាក់គណៈ គ្រប់គ្រងធ្វើការវិនិច្ឆ័យអំពីស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុលនិងតម្លៃដែល អាចកំណត់បាននៃទ្រព្យបញ្ចាំណាមួយ។ ឱនភាពតម្លៃនៃទ្រព្យសកម្មនីមួយៗ ត្រូវបានវាយតម្លៃលើគុណ

៣.១ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ឆ) អត្ថសញ្ញាណ និងការវាស់វែងនៃឱនភាពតម្លៃ (ត)

<u>ការវាយតម្លៃទោល និងសមូហភាព</u> (ត)

ប្រយោជន៍ហើយយុទ្ធសាស្ត្រសាកល្បង និងការប៉ាន់ស្មាននៃលំហូរសាច់ប្រាក់ដែលអាចរកបានមកវិញ ត្រូវបានអនុម័តដោយគណៈគ្រប់គ្រងឯករាជ្យ។

សមាសធាតុសមូហភាពនៃសំវិធានធនសម្រាប់ឱនភាពតម្លៃ ត្រូវបានបង្កើតឡើងសម្រាប់៖

- ក្រុមនៃប្រាក់កម្ចីមានលក្ខណៈដូចគ្នា ដែលមិនត្រូវបានចាត់ទុកថាមានលក្ខណៈជាសារវន្តទោល និង
- ក្រុមនៃទ្រព្យសកម្មដែលមានលក្ខណៈជាសារវន្តទោល ប៉ុន្តែមិនបានរកឃើញថាមានឱនភាពតម្លៃ។

សំវិធានធនលើសមូហភាពនៃប្រាក់កម្ចី ដែលមានលក្ខណៈដូចគ្នាត្រូវបានបង្កើតទ្បើងដោយប្រើវិធីសាស្ត្រស្ថិតិ ដូចជាវិធីសាស្ត្រអត្រាបន្ត ឬសម្រាប់បណ្តាំឥណទានតូចៗដែលមានព័ត៌មានមិនគ្រប់គ្រាន់ ឬរួបមន្តផ្អែកលើបទពិសោធន៍អត្រាការខាតបង់យោងតាមនិន្នាការពីមុន។

ក្នុងការវាយតម្លៃសំវិធានធនលើឱនភាពតម្លៃជាសមូហភាព គណៈគ្រប់គ្រងពិចារណាលើកត្តាមួយចំនួនដូចជា គុណភាពឥណទាន ទំហំឥណទាន ការប្រមូលផ្តុំ និងកត្តាសេដ្ឋកិច្ច។ ដើម្បីប៉ាន់ស្មាននូវសំវិធានធនចាំបាច់ ការសន្មត់ត្រូវបានធ្វើឡើងដើម្បីកំណត់អំពីរបៀបដែលការខាតបង់ជាយថាផល ត្រូវបានកំណត់ និងតម្រូវបញ្ចូលប៉ារ៉ាម៉ែត្រ ដែលផ្អែកលើបទពិសោធន៍ពីមុន និងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន។ ភាពត្រឹមត្រូវនៃសំវិធានធន អាស្រ័យលើការសន្មត់ជាគំរូ និងប៉ារ៉ាម៉ែត្រដែលត្រូវបានប្រើក្នុងការកំណត់សំវិធានធនជាសមូហភាព។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

៣. សេចក្តីសង្ខេបពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

<u>ការវាស់វែង</u>

សំវិធានធនលើឱនភាពតម្លៃនៃទ្រព្យសកម្ម វាស់វែងតាមវិធីសាស្ត្ររំលស់ថ្លៃដើម ត្រូវបានគណនាជាភាពខុសគ្នារវាងតម្លៃយោង និងតម្លៃបច្ចុប្បន្នលើលំហូរសាច់ប្រាក់ដែលរំពឹងទុកនាពេលអនាគតដែលបានធ្វើអប្បហារតាមអត្រាការប្រាក់មានប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្ម។

<u>តំហយនៃឱនភាពតម្លៃ និងការលុបចោល</u>

ប្រសិនបើ ក្នុងអំឡុងការិយបរិច្ឆេទបន្តបន្ទាប់ ទឹកប្រាក់ថយចុះនៃឱនភាពតម្លៃ ហើការថយចុះអាចទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលកើតឡើងបន្ទាប់ពីឱនភាពតម្លៃត្រូវបានទទួលស្គាល់ ក្រុមហ៊ុនត្រូវដកចេញការខាតបង់នៃឱនភាពតម្លៃ ដែលបានទទួលស្គាល់ពីមុនដោយផ្ទាល់ ឬដោយនិយ័តភាពគណនីសំវិធានធន។

៣.១ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ឆ) អត្តសញ្ញាណ និងការវាស់វែងនៃឱនភាពតម្លៃ (ត)

<u>តំហយនៃឱនភាពតម្លៃ និងការលុបចោល</u> (ត)

តំហយសំវិធានធន មិនអាចលើសពីតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ដកសំវិធានធន) ដែលលើសពីតម្លៃយោង ដែលបានធ្វើឱនភាពតម្លៃមិនបានទទួលស្គាល់ពីមុន។ ក្រុមហ៊ុនទទួលស្គាល់ទឹកប្រាក់កែតម្រូវនៅក្នុងចំណេញ ឬខាត។

ក្រុមហ៊ុនលុបចោលបំណុល ឬបំណុលវិនិយោគទាំងផ្នែកខ្លះ ឬទាំងអស់ដែលពាក់ព័ន្ធនឹងសំវិធានធនលើឱនភាពតម្លៃ នៅពេលដែលគណៈគ្រប់គ្រងកំណត់ថាមិនមានលទ្ធភាពមិនអាចប្រមូលមកវិញ។

៣.២ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ត្រូវបានវាស់វែងដំបូងតាមថ្លៃដើម។ ថ្លៃដើម រួមបញ្ចូលចំណាយដែលត្រូវបានពាក់ព័ន្ធដោយផ្ទាល់ដើម្បីនាំយកទ្រព្យសកម្មនោះ និងលក្ខខណ្ឌការប្រើប្រាស់ចាំបាច់សម្រាប់ប្រតិបត្តិការប្រើប្រាស់ដែលបានគ្រោងទុកដោយគណៈគ្រប់គ្រង។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

៣. សេចក្តីសង្ខេបពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

ក្រុមហ៊ុនរួមបញ្ចូលនៅក្នុងតម្លៃយោងនៃទ្រព្យសកម្ម លើចំណាយការផ្លាស់ប្តូរសមាសធាតុមួយនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារនៅពេលដែលថ្លៃដើមត្រូវបានកើតឡើង ប្រសិនបើច្បាស់ថាអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតនឹងហូរចូលមកក្រុមហ៊ុន។ តម្លៃយោងនៃការផ្លាស់ប្តូរគ្រឿងបន្លាស់មិនត្រូវបានទទួលស្គាល់។ ចំណាយប្រចាំថ្ងៃក្នុងការជួសជុលទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត នៅពេលកើតមាន។ រំលស់ទ្រព្យសម្បត្តិ ត្រូវបានរំលស់ដោយថ្លៃដើមដកតម្លៃកាកសំណល់ធៀបនឹងអាយុកាលប្រើប្រាស់រំពឹងទុកដែលនៅសល់។ ចន្លោះអាយុកាលប្រើប្រាស់មានដូចខាងក្រោម៖

	អត្រារំលស់ (ឆ្នាំ)
ការកែលម្អអគារ	២០
យានយន្ត	៤
បរិក្ខារកុំព្យូទ័រ និងបរិក្ខារអេឡិចត្រូនិច	៥
គ្រឿងសង្ហារឹម និងបរិក្ខារ	២

តម្លៃកាកសំណល់ អាយុកាលប្រើប្រាស់ និងវិធីសាស្ត្ររំលស់ ត្រូវបានត្រួតពិនិត្យឡើងវិញនៅរៀងរាល់ចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ និងធ្វើនិយ័តកម្មតាមការគួរ។

៣.២ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

ចំណេញ និងខាតនៃការលក់ ត្រូវបានកំណត់ដោយប្រៀបធៀបតម្លៃលក់ និងតម្លៃយោង និងត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

៣.៣ ឱនភាពតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មដែលបានរំលស់ ត្រូវបានត្រួតពិនិត្យឡើងវិញ នៅចុងបញ្ចប់នៃកាលបរិច្ឆេទរបាយការណ៍នីមួយៗ ដើម្បីកំណត់ថា តើមានការចង្អុលបង្ហាញពីឱនភាពតម្លៃដែរឬទេ។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ(ត)

៣. សេចក្តីសង្ខេបពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

ប្រសិនបើមានការចង្អុលបង្ហាញបែបនេះ ទ្រព្យសកម្មត្រូវបានធ្វើឱនភាពតម្លៃ និងតម្លៃយោងនៃទ្រព្យសកម្ម (ឬអង្គភាពបង្កើតសាច់ប្រាក់ដែលទ្រព្យសកម្មត្រូវបានបែងចែក) ត្រូវបានធ្វើតេស្តឱនភាពតម្លៃ។ ការខាតបង់ឱនភាពតម្លៃ ត្រូវបានទទួលស្គាល់ចំនួនទឹកប្រាក់ដែលតម្លៃយោងនៃទ្រព្យសកម្មលើសចំនួនទឹកប្រាក់ដែលអាចប្រមូលបានមកវិញ។ចំនួនទឹកប្រាក់ដែលអាចប្រមូលបានមកវិញ គឺខ្ពស់ជាងតម្លៃសមស្របនៃអង្គភាពបង្កើតសាច់ប្រាក់ ដកថ្លៃដើមនៃការលក់ និងតម្លៃក្នុងការប្រើប្រាស់។ គោលបំណងនៃការត្រួតពិនិត្យឱនភាពតម្លៃទ្រព្យសកម្ម ត្រូវបានបែងចែកពីតម្លៃទាប ដែលត្រូវបានកំណត់លំហូរសាច់ប្រាក់ផ្សេងៗគ្នា(អង្គភាពបង្កើតសាច់ប្រាក់)។ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ក្រៅពីមូលនិធិពាណិជ្ជកម្ម ដែលទទួលរងឱនភាពតម្លៃ ត្រូវបានត្រួតពិនិត្យលើការកត់បញ្ច្រាស់នៃឱនភាពតម្លៃនៅចុងបញ្ចប់នៃកាលបរិច្ឆេទរបាយការណ៍នីមួយៗ។

៣.៤ ទ្រព្យសកម្មទុកសម្រាប់ជួល

ទ្រព្យសម្បត្តិដែលរក្សាទុកសម្រាប់ជួលរួមមាន ម៉ូតូ និងយានជំនិះកង់បី។ ទ្រព្យសកម្មដែលកាន់កាប់សម្រាប់ការជួលត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្ម ហើយត្រូវបានបញ្ជាក់ក្នុងតម្លៃទាប និងតម្លៃសុទ្ធដែលអាចសម្រេចបាន។ ការចំណាយរួមមានការចំណាយលើការទិញ និងថ្លៃដើមផ្សេងទៀតដែលពាក់ព័ន្ធដោយផ្ទាល់។តម្លៃសុទ្ធដែលអាចសម្រេចបានគឺជាការប៉ាន់ប្រមាណតម្លៃលក់ក្នុងដំណើរការអាជីវកម្មធម្មតា តិចជាងការចំណាយប៉ាន់ស្មានដើម្បីលក់ទ្រព្យសកម្ម។

៣.៥ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើរតាមតម្រូវការ និងសាច់ប្រាក់រយៈពេលខ្លីផ្សេងៗ ដែលអាចងាយបំលែងទៅជាសាច់ប្រាក់ ជាមួយនឹងកាលកំណត់រយៈពេលបីខែ ឬតិចជាងនឹង។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

៣. សេចក្តីសង្ខេបពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

៣.៦ ប្រាក់តម្កល់កាតព្វកិច្ច

ប្រាក់តម្កល់កាតព្វកិច្ច តំណាងឲ្យប្រាក់តម្កល់ធានាមូលធន និងសាច់ប្រាក់ដែលរក្សាទុកជាមួយធនាគារជាតិនៃកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ប្រាក់តម្កល់កាតព្វកិច្ចមិនត្រូវបានប្រើប្រាស់សម្រាប់ផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុន ហេតុដូច្នេះមិនត្រូវបានចាត់ទុកជាផ្នែកមួយនៃសាច់ប្រាក់និងសាច់ប្រាក់សមមូលសម្រាប់បង្ហាញក្នុងរបាយការណ៍លំហូរសាច់ប្រាក់ឡើយ។

សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា ត្រូវបានគិតតាមថ្លៃដើមរំលស់ ដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

៣.៧ ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រានៅថ្លៃដើមដែលបានធ្វើរំលស់តាមវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

៣.៨ គណនីត្រូវបង់ផ្សេងៗ

គណនីត្រូវបង់ផ្សេងៗ ត្រូវបានទទួលស្គាល់ដំបូងនៅតម្លៃប្រតិបត្តិការ និងទទួលស្គាល់ជាបន្តបន្ទាប់ នៅថ្លៃដើមដែលបានធ្វើរំលស់តាមវិធីសាស្ត្រការប្រាក់មានប្រសិទ្ធិភាព។

៣.៩ ដើមទុន

ភាគហ៊ុនធម្មតា ត្រូវបានចាត់ថ្នាក់ជាមូលធន។

ឧបករណ៍មូលបត្រកម្មសិទ្ធិ ត្រូវបានវាស់វែងតម្លៃសមស្របនៃសាច់ប្រាក់ ឬធនធានដទៃទៀតបានទទួលឬនឹងទទួល ថ្លៃដើមផ្គាល់សុទ្ធនៃការបោះផ្សាយឧបករណ៍មូលបត្រកម្មសិទ្ធិ។ ប្រសិនបើការទូទាត់ត្រូវបានពន្យា និងតម្លៃនៃសាច់ប្រាក់ជាសារវន្ត ការវាស់វែងដំបូងត្រូវបានកំណត់តាមមូលដ្ឋានបច្ចុប្បន្ន។

៣.១០ ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងបទប្បញ្ញត្តិត្រូវបានបង្កើតសម្រាប់ភាពខុសគ្នានៃសំវិធានធន រវាងឱនភាពតម្លៃនៃឥណទានដែលកំណត់ឡើងដោយអនុលោមតាម CIFRS for SMEs និងសំវិធានធនតាមបទប្បញ្ញត្តិ ស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ខ៧-០១៧-៣៤៤

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

៣. សេចក្តីសង្ខេបពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

៣.១០ ទុនបម្រុងតាមបទប្បញ្ញត្តិ (ត)

ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរណែនាំលេខ ៧-០១៨-០០១ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធននៃឱនភាពតម្លៃសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

យោងលើគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ឥណទានទៅអតិថិជនទាំងអស់ ត្រូវបានចាត់ថ្នាក់ដោយផ្អែកលើសមត្ថភាពនៃការសងបំណុលរបស់ដៃគូ ហើយចំនួនថ្ងៃដែលបានហួសកាលកំណត់សងត្រូវបានចាត់ថ្នាក់ដូចខាងក្រោម៖

ចំណាត់ថ្នាក់ឥណទានរយៈខ្លី (តិចជាង ឬស្មើមួយឆ្នាំ)៖	**ចំនួនថ្ងៃដែលបានហួសកាលកំណត់សង**	**សំវិធានធន**
ធម្មតា/ស្តង់ដារ	តិចជាង១៥ ថ្ងៃ	១%
ឃ្លាំមើល	១៥ ថ្ងៃ - ៣០ ថ្ងៃ	៣%
ក្រោមស្តង់ដារ	៣១ ថ្ងៃ - ៦០ ថ្ងៃ	២០%
ជាប់សង្ស័យ	៦១ ថ្ងៃ - ៩០ ថ្ងៃ	៥០%
បាត់បង់	លើសឬស្មើ៩១ថ្ងៃ	១០០%

ចំណាត់ថ្នាក់ឥណទានរយៈវែង (លើពីមួយឆ្នាំ)៖	**ចំនួនថ្ងៃដែលបានហួសកាលកំណត់សង**	**សំវិធានធន**
ធម្មតា/ស្តង់ដារ	តិចជាង៣០ ថ្ងៃ	១%
ឃ្លាំមើល	លើសឬស្មើ៣០ ថ្ងៃ - ៨៩ ថ្ងៃ	៣%
ក្រោមស្តង់ដារ	លើសឬស្មើ៩០ ថ្ងៃ - ១៧៩ ថ្ងៃ	២០%
ជាប់សង្ស័យ	លើសឬស្មើ១៨០ថ្ងៃ - ៣៥៩ ថ្ងៃ	៥០%
បាត់បង់	លើស៣៥៩ថ្ងៃ	១០០%

៣. សេចក្តីសង្ខេបពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

៣.១០ ទុនបម្រុងតាមបទប្បញ្ញត្តិ (ត)

យោងតាមប្រកាសនេះ ក្រុមហ៊ុនគួរធ្វើការប្រៀបធៀបសំវិធានធន ដែលបានគណនាស្របតាម
CIFRS for SMEs និងសំវិធានធនតាមបទប្បញ្ញត្តិ និង៖

(ក) ក្នុងករណីសំវិធានធនតាមបទប្បញ្ញត្តិ ទាបជាងសំវិធានធនដែលគណនាតាម CIFRS for SMEs ក្រុមហ៊ុនធ្វើការកត់ត្រាសំវិធានធនដែលគណនាតាម CIFRS for SMEs និង

(ខ) ក្នុងករណីសំវិធានធនតាមបទប្បញ្ញត្តិ ខ្ពស់ជាងសំវិធានធនដែលគណនាតាម CIFRS for SMEs ក្រុមហ៊ុនធ្វើការកត់ត្រាសំវិធានធនដែលគណនាតាម CIFRS for SMEs ហើយផ្ទេរចំនួនលម្អៀងពីប្រាក់ចំណេញរក្សាទុក ទៅទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងគណនីមូលធនរបស់ម្ចាស់ក្រុមហ៊ុននៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

៣.១១ សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់ នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចបច្ចុប្បន្ន (ច្បាប់ ឬ គំនិតនៃច្បាប់) ដែលបានមកពីព្រឹត្តិការណ៍អតីតកាល ដែលអាចជាលំហូរធាតុចេញនៃធនធានសេដ្ឋកិច្ច ដែលតម្រូវឲ្យទូទាត់កាតព្វកិច្ច និងចំនួនទឹកប្រាក់នៃកាតព្វកិច្ច ដែលអាចប៉ាន់ស្មានគួរឲ្យទុកចិត្តបាន។

ប្រសិនបើការប៉ះពាល់នៃ តម្លៃទឹកប្រាក់ជាសារវន្តសំវិធានធនដែលត្រូវបានកំណត់ដោយពឹងផ្អែកលើលំហូរសាច់ប្រាក់នាពេលអនាគតដែលរំពឹងទុក ដើម្បីទូទាត់កាតព្វកិច្ច ត្រូវបានបញ្ចុះតម្លៃដោយប្រើអត្រាពន្ធបច្ចុប្បន្នជាមុន ដែលបានឆ្លុះបញ្ចាំងពីការវាយតម្លៃទឹកប្រាក់បច្ចុប្បន្ន និងហានិភ័យនៃបំណុល ជាក់លាក់។

សំវិធានធនត្រូវបានពិនិត្យឡើងវិញ នៅការិយបរិច្ឆេទរាយការណ៍នីមួយៗ និងកែសម្រួលដើម្បីឆ្លុះបញ្ចាំងពីការរំពឹងទុកនាពេលបច្ចុប្បន្ន។ ប្រសិនបើលំហូរធាតុចេញនៃធនធានសេដ្ឋកិច្ច មិនត្រូវបានទូទាត់កាតព្វកិច្ច សំវិធានធនត្រូវបានកត់បញ្ច្រាស់។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ(ត)

៣. សេចក្តីសង្ខេបពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

៣.១២ ការប្រាក់

ចំណូល និងចំណាយការប្រាក់ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព។ "ការប្រាក់មានប្រសិទ្ធភាព" គឺជាអត្រា ដែលធ្វើអប្បហារលើការទូទាត់ និងចំណូលដែលបានប៉ាន់ស្មាននាពេលអនាគត តាមរ

យៈអាយុកាលដែលរំពឹងទុកនៃទ្រព្យសកម្ម ហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ឬក្នុងរយៈពេលខ្លីសមស្របមួយ) ទៅនឹងតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ។

នៅពេលគណនាលើការប្រាក់មានប្រសិទ្ធភាព ក្រុមហ៊ុនត្រូវប៉ាន់ស្មានលើលំហូរសាច់ប្រាក់នាពេលអនាគតដោយពិចារណាលើលក្ខខណ្ឌកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុប៉ុន្តែមិនមែនការខាតបង់លើឥណទាននាពេលអនាគតទេ។

ការគណនាលើការប្រាក់មានប្រសិទ្ធភាព រួមបញ្ចូលថ្លៃដើមប្រតិបត្តិការ និងថ្លៃសេវា និងពិន្ទុដែលបានបង់ឬទទួល ដែលជាផ្នែកសំខាន់នៃការប្រាក់មានប្រសិទ្ធភាព។ ថ្លៃដើមប្រតិបត្តិការ រួមបញ្ចូលថ្លៃដើមបន្ថែមដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការទិញ ឬបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ។

៣.១៣ កម្រៃជើងសារ

ចំណូល នឹងចំណាយកម្រៃជើងសារ ដែលភ្ជាប់នឹងអត្រាការប្រាក់មានប្រសិទ្ធភាពលើទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានបញ្ចូលទៅក្នុងអត្រាការប្រាក់មានប្រសិទ្ធភាព។ ចំណូលកម្រៃ ជើងសារ ត្រូវបានទទួលស្គាល់ នៅពេលសេវាកម្មពាក់ព័ន្ធដែលត្រូវបានបំពេញ។ ប្រសិនបើកិច្ចសន្យាឥណទាន មិនរំពឹងថានឹងមានការដកប្រាក់កម្ចី នោះថ្លៃសេវាដែលទាក់ទងនឹងប្រាក់កម្ចី ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានថេរលើអាយុកាលនៃកិច្ចសន្យាឥណទាន។កម្រៃចំណាយ និងជើងសារផ្សេងៗ ពាក់ព័ន្ធនឹងចំណាយប្រតិបត្តិការ និងថ្លៃសេវាកម្ម ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលសេវាកម្មបានទទួល។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ(ត)

៣. សេចក្តីសង្ខេបពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

៣.១៤ អត្ថប្រយោជន៍បុគ្គលិក

កាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លីពាក់ព័ន្ធនឹង ប្រាក់ឈ្នួល ប្រាក់ខែ វិភាគទាន សន្តិសុខសង្គម ប្រាក់រង្វាន់ប្រចាំឆ្នាំ ការឈប់សម្រាកប្រចាំឆ្នាំ ការឈប់សម្រាកឈឺ និង អត្ថប្រយោជន៍មិនមែនរូបិយវត្ថុ ត្រូវបានទទួលស្គាល់ជាចំណាយ នៅក្នុងរបាយការណ៍ចំណេញ ឬខាត នៅពេលដែលនិយោជិកបានផ្តល់សេវាកម្មដល់ក្រុមហ៊ុន។

៣.១៥ ភតិសន្យា

ភតិតសន្យាដែលត្រូវបានរក្សាទុកនៃហានិភ័យ និងភាពជាម្ចាស់កម្មសិទ្ធិ ដោយភតិក: ត្រូវបានចាត់ថ្នាក់ជាចំណាយប្រតិបត្តិការ។ ការទូទាត់នៃចំណាយប្រតិបត្តិការ (ផលប្រយោជន៍ដែលទទួលបានពីភតិក:សុទ្ធ) ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតតាមវិធីសាស្ត្ររំលស់ថេរលើរយៈពេលនៃភតិសន្យា។

៣.១៦ ពន្ធក្នុងគ្រា និងពន្ធពន្យារ

ចំណាយពន្ធលើប្រាក់ចំណូល ឬឥណទានក្នុងឆ្នាំ គឺជាពន្ធដែលរំពឹងថានឹងត្រូវបង់ពន្ធលើប្រាក់ចំណូលក្នុងអំឡុងការិយបរិច្ឆេទ ដោយពឹងផ្អែកលើអត្រាពន្ធលើប្រាក់ចំណូលដែលត្រូវបានអនុម័ត ធ្វើនិយ័តកម្មលើបម្រែបម្រួលទ្រព្យសកម្មពន្ធពន្យារ និងបំណុលដែលបានមកពីភាពខុសគ្នាបណ្តោះអាសន្ន និងការខាតបង់ពន្ធដែលមិនទាន់ប្រើប្រាស់។

ពន្ធពន្យារ ត្រូវបានទទួលស្គាល់ លើភាពខុសគ្នាបណ្តោះអាសន្ន ដែលកើតឡើងរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្មនិងបំណុល និងតម្លៃយោងនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងការខាតបង់ពន្ធដែលមិនទាន់ប្រើ ឬឥណទានពន្ធរបស់ក្រុមហ៊ុន។ ពន្ធពន្យារ ត្រូវបានកំណត់ដោយប្រើអត្រាពន្ធ និងច្បាប់ ដែលត្រូវបានអនុម័ត ឬអនុម័តយ៉ាងសំខាន់នាការិយបរិច្ឆេទរាយការណ៍។

ទ្រព្យសកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់ នៅពេលដែលមានចំនួនទឹកប្រាក់ជាប់ពន្ធនាពេលអនាគត ត្រូវបានប្រើប្រាស់សម្រាប់ភាពខុសគ្នាបណ្តោះអាសន្ន និងការខាត។

ពន្ធក្នុងគ្រា និងទ្រព្យសកម្មពន្ធពន្យារ និងបំណុល ត្រូវបានកាត់កង នៅពេលដែលមានសិទ្ធិស្របច្បាប់សម្រាប់កាត់កង ហើយក្រុមហ៊ុនអាចបង្ហាញដោយមិនចាំបាច់ចំណាយ ឬ

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ(ត)

៣. សេចក្តីសង្ខេបពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

និងប្រឹងប្រែងហួសប្រមាណដែលនឹងទូទាត់ជាមូលដ្ឋានសុទ្ធ ឬដើម្បីទទួលស្គាល់ទ្រព្យសម្បត្តិ និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

ពន្ធក្នុងគ្រា និងពន្ធពន្យារ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត លើកលែងដែលពាក់ព័ន្ធជាកត្តា ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លម្អិតផ្សេង ឬក្នុងមូលធនផ្ទាល់។ ក្នុងករណីនេះ ពន្ធត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លម្អិតផ្សេង ឬក្នុងមូលធនផ្ទាល់រៀងគ្នា។

៣.១៧ ការប្តូរប្រតិបត្តិការរូបិយប័ណ្ណបរទេស

ប្រតិបត្តិការរូបិយប័ណ្ណបរទេសក្នុងឆ្នាំ ត្រូវបានប្តូរតាមអត្រាប្តូរប្រាក់ ដែលមាននៅថ្ងៃប្រតិបត្តិការ។ ទ្រព្យសកម្ម និងបំណុលរូបិយវត្ថុដែលគិតជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរតាមអត្រាប្តូរប្រាក់បរទេសដែលកំណត់នៅចុងការិយបរិច្ឆេទ។ ចំណេញ ឬខាតនៃការប្តូររូបិយប័ណ្ណត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត។

ទ្រព្យសកម្មនិងបំណុលមិនមែនរូបិយវត្ថុដែល បានវាស់វែងតាមវិធីសាស្ត្រថ្លៃដើមប្រវត្តិសាស្ត្រជារូបិយប័ណ្ណបរទេសត្រូវបានប្តូរដោយប្រើ អត្រាប្តូរប្រាក់បរទេសដែកំណត់នៅថ្ងៃប្រតិបត្តិការ។ ទ្រព្យសកម្ម និងបំណុល មិនមែនរូបិយវត្ថុដែលគិតជារូបិយប័ណ្ណបរទេស ត្រូវបានកំណត់តាមតម្លៃសមស្របត្រូវប្តូរតាមអត្រាប្តូរប្រាក់បរទេសដែលកំណត់នៅថ្ងៃដែលតម្លៃសមស្របបានកំណត់។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ(ត)

៤. ការវិនិច្ឆ័យ ការប៉ាន់ប្រមាណ និងការសន្មតគណនេយ្យសំខាន់ៗ

ចំនុចសំខាន់នៃការប៉ាន់ប្រមាណ ភាពមិនច្បាស់លាស់ និងការវិនិច្ឆ័យសំខាន់ក្នុងការអនុវត្តតាមគោលនយោបាយគណនេយ្យ ដែលមានផលប៉ះពាល់ខ្លាំងក្នុងការកំណត់ចំនួន ដែលបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុមានដូចខាងក្រោម៖

៤.១ ការវាយតម្លៃគម្រូអាជីវកម្ម

ភតិសន្យាហិរញ្ញវត្ថុត្រូវទទួលតាងដោយភតិសន្យាហិរញ្ញវត្ថុទៅអតិថិជន ដែលថាអតិថិជនរក្សាភាពជាម្ចាស់នៃទ្រព្យសម្បត្តិតាំងពីដើម និង ក្នុងអំឡុងពេលឥណទាន។ ទោះបីជាការរៀបចំប្រតិបត្តិការទាំងនេះជាមួយអតិថិជនហាក់ដូចជា ប្រតិបត្តិការឥណទានក៏ដោយ ក៏គណៈគ្រប់គ្រងជឿជាក់ថាក្រុមហ៊ុនប្រតិបត្តិក្នុងវិសាលភាពនៃការជួលហិរញ្ញវត្ថុដូចដែលបានកំណត់នៅក្នុងប្រកាសលេខB7-011-241 ស្តីពីអាជីវកម្មជួលហិរញ្ញវត្ថុដែលចេញដោយធនាគារជាតិនៃកម្ពុជា។

៤.២ សំវិធានធនសំរាប់ការខាតបង់ឱនភាពតម្លៃលើភតិសន្យាហិរញ្ញវត្ថុត្រូវទទួល

ក្រុមហ៊ុនបានធ្វើសំវិធានធនសំរាប់ការខាតបង់ឱនភាពតម្លៃលើភតិសន្យាហិរញ្ញវត្ថុត្រូវទទួល ដោយផ្អែកលើការវាយតម្លៃនៃការទទួលបានមកវិញ។ ឱនភាពតម្លៃត្រូវបានអនុវត្តទៅលើការភតិសន្យាហិរញ្ញវត្ថុត្រូវទទួល ក្នុងព្រឹត្តិការឬការផ្លាស់ប្តូរក្នុងកាលៈទេសៈបង្ហាញថាតម្លៃយោងអាចនឹងមិនអាចទទួលបានមកវិញ។ គណៈគ្រប់គ្រងធ្វើការវិភាគជាពិសេសទៅលើចំនួនដែលបានប៉ាន់ប្រមាណ និងពេលវេលានៃលំហូរសាច់ប្រាក់ព្រមទាំងតម្លៃដែលអាចសម្រេចបានសុទ្ធនៃតម្លៃវត្ថុបញ្ចាំ នៅពេលធ្វើការវិនិច្ឆ័យដើម្បីវាយតម្លៃភាពមិនគ្រប់គ្រាន់នៃឱនភាពតម្លៃ។ នៅពេលដែលការរំពឹងទុកខុសពីការប៉ាន់ស្មានដើម ភាពខុសគ្នានេះនឹងប៉ះពាល់ដល់តម្លៃយោងនៃភតិសន្យាហិរញ្ញវត្ថុត្រូវទទួលទៅអតិថិជន។

៤.៣ ពន្ធលើប្រាក់ចំណូល

ការវិនិច្ឆ័យដ៏សំខាន់ គឺចាំបាច់ក្នុងការកំណត់ទាយជ្ជទានលើមូលធន និងការកាត់ចេញនៃការចំណាយណាមួយក្នុងកំឡុងពេលប៉ាន់ប្រមាណនៃសំវិធានធនពន្ធលើប្រាក់ចំណូល។ ក្នុងនោះមានប្រតិបត្តិការ និងការគណនាជាច្រើន ពោលគឺការកំណត់ពន្ធចុងក្រោយ មិនមានភាពប្រាកដប្រជាក្នុងកំឡុងពេលដំណើរការអាជីវកម្មធម្មតា។ នៅពេលដែលលទ្ធផលចុងក្រោយ

នៃពន្ធត្រូវបង់អាចខុសពីការប៉ាន់ស្មានដំបូង ភាពខុសគ្នានេះអាចប៉ះពាល់ដល់ពន្ធក្នុងគ្រា និងពន្ធពន្យារក្នុងអំឡុងពេលដែលការកំណត់ពន្ធនោះបានកើតឡើង។

ពន្ធលើប្រាក់ចំណូលរបស់ក្រុមហ៊ុន ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ ២១នៃរបាយការណ៍ហិរញ្ញវត្ថុ។

៤.៤ ការទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារ

ទំហំនៃទ្រព្យសកម្មពន្ធពន្យារពេលអាចត្រូវបានទទួលស្គាល់គឺ ផ្អែកលើការវាយតម្លៃនៃលទ្ធភាពដែលថាពន្ធលើប្រាក់ចំណូលនាពេលអនាគត អាចនឹងមានសំរាប់ទូទាត់ទៅនឹង ភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់បន្ថយបាន និងការខាតបង់យោងនៃពន្ធអាចត្រូវបានប្រើប្រាស់។ លើសពីនេះទៀត ការវិនិច្ឆ័យដ៏សំខាន់ត្រូវបានតម្រូវឲ្យវាយតម្លៃផលប៉ះពាល់នៃភាពស្របច្បាប់ ឬ សេដ្ឋកិច្ច ឬ ភាពមិនប្រាកដប្រជាណាមួយនៅក្នុងដែនកំណត់ពន្ធផ្សេងៗ។

ការិយាល័យកណ្តាល

ផ្ទះលេខ ៨១EoE1E2 ផ្លូវជាតិលេខ៦A ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

ទូរស័ព្ទ:០២៣ ៩០១ ៧៤៤

អ៊ីម៉ែល:

សាខាទី ១ បាត់ដំបង

ផ្ទះលេខ ១២១ ផ្លូវជាតិលេខ៥ ក្រុម១ ភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ:០២៣ ៩០១ ៧៤៤

អ៊ីម៉ែល:


RAFCO
CAMBODIA